# ការដាច់ភ្លើង៖ ការប្រើប្រាស់ប្រេងឥន្ទនៈជំនួស និងម៉ាស៊ីនអគ្គិសនី ដោយសុវត្ថិភាព

## ព័ត៌មានសហគមន៍

នៅពេលដាច់ភ្លើងកើតមានឡើង ជាទូទៅ ដោយសារតែអាកាសធាតុ)មិនល្អ (ពេលខ្លះគេប្រើប្រភពប្រេងឥន្ទនៈជំនួស ឬម៉ាស៊ីនអគ្គិសនី ដើម្បីចម្អិនម្ហូបអាហារ បំភ្លឺ កម្ដៅ ឬជាថាមពលអគ្គិសនី។

ម៉ាស៊ីនភ្លើងចល័តអាចបន្តសកម្មភាពធម្មតាមួយចំនួន ទោះជាយ៉ាងណាក៏ដោយ វាជាការសំខាន់ដែលត្រូវប្រើម៉ាស៊ីនភ្លើងដោយប្រុងប្រយ័ត្ន។

ម៉ាស៊ីនភ្លើងប្រើប្រេងសាំង ឬប្រេងម៉ាស៊ូតអាចបញ្ចេញឧស្ម័នកាបោនម៉ូណូអុកស៊ីត (carbon monoxide) ដូច្នេះ**ត្រូវប្រើប្រាស់វានៅទីកន្លែងក្រៅផ្ទះដែលមានខ្យល់ចេញចូលល្អ** ហើយនៅឆ្ងាយពីបង្អួចបើកចំហ ហើយមានប្រហោងខ្យល់ចេញចូល។

គេមិនអាចមើលឃើញឧស្ម័នកាបូនម៉ូណូស៊ីតឡើយ  ហើយអ្នកក៏មិនអាចហិតក្លិនដឹងដែរ។ ប្រសិនបើវាកើតឡើងនៅក្នុងផ្ទះ រោងឡាន ឬការ៉ាវ៉ាន វាអាចបង្កឲ្យមានជំងឺ ការបាត់បង់ស្មារតី និងស្លាប់ភ្លាមៗ។ សូមនឹកគិតដល់សត្វចិញ្ចឹម ព្រមទាំងក្រុមគ្រួសាររបស់អ្នក។

**កុំប្រើប្រាស់គ្រឿងឧបករណ៍ដែលផលិតឡើងសម្រាប់ការប្រើប្រាស់ក្រៅផ្ទះយកមកប្រើក្នុងផ្ទះ** បន្ទប់ក្រោមដី  រោងឡាន ការ៉ាវ៉ាន ឬតង់ក្រណាត់ ឬនៅខាងក្រៅក្បែរបង្អួចបើកចំហ។ គ្រឿងឧបករណ៍ទាំងនេះដូចជាម៉ាស៊ីនភ្លើង ប្រដាប់អាំងសាច់ ចង្រ្កានសម្រាប់បោះជំរំ ឬប្រេងសាំងផ្សេងទៀត ឧស្ម័ន LP ឧស្ម័នធម្មជាតិ ឬឧបករណ៍ដុតធ្យូង គួរប្រើប្រាស់ទៅតាមការណែនាំពីក្រុមហ៊ុនផលិត។

## ម៉ាស៊ីនភ្លើង

ទោះបីជាម៉ាស៊ីនភ្លើងមានប្រយោជន៍យ៉ាងច្រើនក៏ដោយ ប្រសិនបើមិនបានប្រើប្រាស់វាដោយសុវត្ថិភាពទេ ម៉ាស៊ីនភ្លើងចល័តទាំងនេះអាចបណ្ដាលឲ្យ៖

- មានការពុលដោយឧស្ម័នកាបូនម៉ូណូអុកស៊ីតចេញពីផ្សែងម៉ាស៊ីន។
- ភ្លើងឆក់ ឬខ្សែភ្លើងឆក់។
- អគ្គិភ័យ។

អ្នករស់នៅក្នុងផ្ទះត្រូវអនុវត្តតាមការណែនាំដែលដាក់ភ្ជាប់មកជាមួយម៉ាស៊ីនភ្លើង ដើម្បីធានាដល់ការប្រើប្រាស់ដោយសុវត្ថិភាព។

## ការទិញម៉ាស៊ីនភ្លើង

ម៉ាស៊ីនភ្លើងដែលបានដំឡើងជាអចិន្ត្រៃយ៍ គឺជាម៉ាស៊ីនភ្លើងល្អសមស្របបំផុតសម្រាប់គេហដ្ឋាន ពេលណាមានការដាច់ភ្លើង។

**មានតែជាងភ្លើងដែលមានអាជ្ញាបណ្ណប៉ុណ្ណោះ ដែលគួរតភ្ជាប់ម៉ាស៊ីនភ្លើងជាអចិន្ត្រៃយ៍។**

## ការប្រើប្រាស់ម៉ាស៊ីនភ្លើងចល័តដោយសុវត្ថិភាព

- **កុំប្រើប្រាស់ម៉ាស៊ីនភ្លើងចល័តនៅក្នុងផ្ទះឲ្យសោះ។** ការនេះរួមបញ្ចូលទាំងនៅក្នុងរោងឡាន ចំណតរថយន្តក្បែរផ្ទះ បន្ទប់ក្រោមដី កន្លែងតូចចង្អៀត ឬទីកន្លែងបិទជិត ឬទីកន្លែងបិទជិតភាគខ្លះ ទោះបីជាកន្លែងមានខ្យល់ចេញចូលក្ដី។
- ត្រូវប្រើប្រាស់ម៉ាស៊ីនភ្លើងឲ្យឆ្ងាយពីបង្អួច។
- សូមអានសេចក្ដីណែនាំពីរោងចក្រផលិត មុននឹងប្រើប្រាស់។
- កុំប្រើប្រាស់ម៉ាស៊ីនភ្លើងហួសបន្ទុក។
- បិទម៉ាស៊ីនភ្លើងនៅពេលចាក់ប្រេងបំពេញ ឬនៅពេលមិនប្រើប្រាស់វា។

ការបើកទ្វារ និងបង្អួចពុំអាចទប់ស្កាត់ឧស្ម័នកាបូនម៉ូណូអុកស៊ីតមិនឲ្យកើតមានឡើងនៅក្នុងផ្ទះបានឡើយ។ យល់ល្អ គួរដំឡើងឧបករណ៍ប្រកាសអាសន្នអំពីឧស្ម័នកាបូនម៉ូណូអុកស៊ីត ដែលមានដំណើរការដោយថ្មភ្លើងនៅក្នុងផ្ទះរបស់អ្នក ដើម្បីប្រាប់អ្នកឲ្យប្រុងប្រយ័ត្នពេលណាកម្រិតឧស្ម័នកាបូនម៉ូណូអុកស៊ីតបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាព។ ត្រូវធ្វើតេស្តថ្មភ្លើងឲ្យបានញឹកញាប់ និងប្ដូរថ្មីពេលណាចាំបាច់។

## ដើម្បីជៀសវាងខ្សែភ្លើងឆក់

- រក្សាទុកម៉ាស៊ីនភ្លើងឲ្យស្ងួត និងមិនប្រើវានៅពេលភ្លៀង។
- ដើម្បីការពារម៉ាស៊ីនភ្លើងមិនឲ្យសើម ប្រើវានៅលើផ្ទៃកម្រាលស្ងួតក្រោមសំណង់រាងដូចក្ដោងបើកចំហ ដូចជាតង់ដែលបានដំឡើងនៅលើបង្គោល ។

Health and Human Services

- សម្ងួតដៃរបស់អ្នកជានិច្ច មុននឹងប៉ះពាល់ម៉ាស៊ីនភ្លើង។

## ការចាក់បំពេញប្រេងម៉ាស៊ីនភ្លើង

- ត្រូវប្រាកដថាបានបិទម៉ាស៊ីនភ្លើង ហើយទុកវាឲ្យត្រជាក់មុននឹងចាក់បំពេញប្រេង។ ប្រេងសាំងដែលកំពប់នៅលើគ្រឿងម៉ាស៊ីនភ្លើងក្តៅអាចឆេះបាន។
- រក្សាទុកប្រេងសាំងនៅខាងក្រៅផ្ទះ នៅក្នុងរោងចាក់សោជាប់ ឬទីកន្លែងផ្សេងទៀតដែលបានការពារ។
- កុំរក្សាទុកប្រេងឥន្ធនៈណាមួយនៅក្បែរឧបករណ៍ដុតប្រេងឥន្ធនៈ )ដូចជាម៉ាស៊ីនកម្តៅទឹកប្រើឧស្ម័នធម្មជាតិ ឬនៅក្បែរឡាននៅក្នុងរោងឡាន(។

## ការប្រើប្រាស់ឧបករណ៍ដែលតភ្ជាប់ទៅនឹងម៉ាស៊ីនភ្លើង

ប្រសិនបើវិលត្រឡប់ទៅទីកន្លែងអចលនទ្រព្យដែលបានរងការខូចខាតយ៉ាងដំណំដោយភ្លើងឆេះ ឬខ្យល់បក់ខ្លាំង វាជាការសំខាន់ដែលត្រូវពិនិត្យមើល ខ្សែភ្លើង និងបរិក្ខារដំឡើងអគ្គិសនីផ្សេងទៀតជាមុនសិន  មុននឹងតភ្ជាប់ ហើយបើកឧបករណ៍ណាមួយ។

លើសពីនេះទៀត អ្នកគួរតែៈ

- ដោតឧបករណ៍ដោយផ្ទាល់ទៅនឹងម៉ាស៊ីនភ្លើង តាមរយៈខ្សែភ្លើងតសម្រាប់ប្រើប្រាស់ក្នុងផ្ទះ និងមុខការធ្ងន់ៗ។
- ប្រើប្រាស់ខ្សែភ្លើងតខ្លីដែលនៅល្អ ហើយមានប្រឡោះឌុយភ្លើងដោតបី។
- ទាញខ្សែភ្លើងតចេញពីដុំរុំខ្សែភ្លើង។

**សូមកុំព្យាយាមបញ្ឆេះភ្លើងអគ្គិសនីបំភ្លឺផ្ទះដោយដោតម៉ាស៊ីនភ្លើងចូលផ្ទាល់ទៅក្នុងឌុយភ្លើងតាមជញ្ជាំង។** ការនេះអាចនាំឲ្យគ្រោះនៅតាមខ្សែភ្លើង និងអាចបង្ក 'ភ្លើងបុកខ្លាំង' ថ្នាក់ធុងន់ធ្ងរដល់រូបអ្នក និងអ្នកជិតខាងរបស់អ្នក។

## ការបង្ការការពុលដោយឧស្ម័នកាបូនម៉ូណូអុកស៊ីត

- ជាដាច់ខាតមិនត្រូវកុំប្រើប្រាស់ចង្ក្រានឧស្ម័ន ឬឡដើម្បីកម្តៅផ្ទះ។
- ជាដាច់ខាតមិនត្រូវប្រើប្រាស់ចង្កើរធ្យូង ឧបករណ៍កម្តៅ hibachi  ភ្លើងគោម ឬចង្ក្រានចល័តសម្រាប់ការបោះជំរុំនៅក្នុងផ្ទះ តង់ ឬការ៉ាវ៉ាន។
- ជាដាច់ខាតមិនត្រូវបើកម៉ាស៊ីនភ្លើង ម៉ាស៊ីនបោកខោអាវ ឬម៉ាស៊ីនណាមួយដែលមានដំណើរការដោយថាមពលប្រេងឥន្ធនៈ នៅក្នុងបន្ទប់ក្រោមដី រោងឡាន ឬសំណង់បិទជិតផ្សេងទៀត ទោះបីជាទ្វារ ឬបង្អួចបើកចំហក៏ដោយ លើកលែងតែឧបករណ៍នេះបានដំឡើងដោយអ្នកជំនាញ ហើយមានប្រហោងខ្យល់ចេញចូល។
- ត្រូវសម្អាតប្រហោងខ្យល់ និងបំពង់ផ្សែងមិនឲ្យមានកំទេចកំទី ជាពិសេសប្រសិនបើមានខ្យល់បក់ខ្លាំង ដូចជាកំទេចកំទីដែលហើរអាចធ្វើឲ្យស្ទះប្រហោងខ្យល់ចេញចូល។
- ជាដាច់ខាតមិនត្រូវបើករថយន្ត ម៉ាស៊ីនភ្លើង ម៉ាស៊ីនបោកខោអាវ ឬម៉ាស៊ីនដែលមានដំណើរការដោយថាមពលប្រេងឥន្ធនៈណាមួយនៅខាងក្រៅបង្អួច ទ្វារបើកចំហ ឬប្រហោងខ្យល់ចេញចូលដែលបញ្ចេញផ្សែងចូលទៅក្នុងទីកន្លែងបិទជិត។
- ជាដាច់ខាតមិនត្រូវបើកម៉ាស៊ីនទុកចោលក្នុងរថយន្តដែលចតនៅក្នុងទីកន្លែងជិតបិទ ឬទីកន្លែងបិទជិតខ្លះ ដូចជារោងឡានជាដើម។
- ប្រសិនបើអ្នកចាប់ផ្តើមមានអារម្មណ៍ឈឺ វិលមុខ ឬខ្សោយ ត្រូវទៅរកកន្លែងមានខ្យល់បរិសុទ្ធភ្លាម ហើយទទួលការពិគ្រោះផ្នែកពេទ្យជាបន្ទាន់។

## សម្រាប់ព័ត៌មានបន្ថែម

- សម្រាប់ព័ត៌មានបន្ថែមអំពីការប្រើប្រាស់ឧស្ម័ន ឬអគ្គិសនីដោយសុវត្ថិភាព សូមទាក់ទង  Energy Safe Victoria   តាមទូរស័ព្ទលេខ 9203 9700 ឬចូលមើលវិបសាយ  www.esv.vic.gov.au
- ដើម្បីរាយការណ៍អំពីការលេចធ្លាយឧស្ម័ន សូមទូរស័ព្ទលេខ 132 771។
- សម្រាប់ព័ត៌មានបន្ថែមអំពីផលប៉ះពាល់សុខភាពដោយសារត្រូវឧស្ម័នកាបូនម៉ូណូអុកស៊ីត សូមទៅជួបពិគ្រោះជាមួយវេជ្ជបណ្ឌិតក្នុងតំបន់របស់អ្នក។
- សម្រាប់ព័ត៌មានសុខភាពទូទៅអំពីឧស្ម័នកាបូនម៉ូណូអុកស៊ីត សូមទាក់ទងជាមួយផ្នែកសុខភាពបរិស្ថាន នៅ Department of Health and Human Services តាមទូរស័ព្ទលេខ  1300 761 874។

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលវិចតូរីយ៉ា  1 Treasury Place, Melbourne។
© រដ្ឋវិចតូរីយ៉ា Department of Health and Human Services ខែកុម្ភៈ ឆ្នាំ២០១៦។